# ការណែនាំអំពីការកម្ចាត់សត្វល្អិតចង្រៃសម្រាប់ម្ចាស់ផ្ទះជួល

# ព័ត៌មានសម្រាប់ម្ចាស់ទ្រព្យជួល និងអ្នកគ្រប់គ្រង

## សូមប្រយ័ត្នចំពោះសត្វល្អិតចង្រៃ!

សត្វល្អិតចង្រៃដូចជា កន្លាត សង្កើច និងពពួកសត្វកកេរជាដើម សុទ្ធតែអាចចម្លងមេរោគដែលអាចធ្វើឱ្យមនុស្សឈឺបាន។ ម្ចាស់ផ្ទះនិងអ្នកជួលផ្ទះ ចាំបាច់ត្រូវសហការគ្នាបង្ការសត្វល្អិតចង្រៃ ឬត្រូវកម្ចាត់ពួកវាចោល និងទប់ស្កាត់ពួកវា ប្រសិនបើទីតាំងទ្រព្យនោះមានសត្វល្អិតចង្រៃរួចហើយ។ ជួនកាល ថ្នាំសម្លាប់សត្វល្អិត ឬសកម្មភាពកម្ចាត់ផ្សេងទៀត ត្រូវបានប្រើប្រាស់ដើម្បីសម្លាប់សត្វល្អិតចង្រៃ។ អ្នកស្នាក់នៅត្រូវតែទទួលបានការជូនដំណឹងយ៉ាងហោចណាស់ 48 ម៉ោងមុនពេលអនុវត្តសកម្មភាពកម្ចាត់សត្វល្អិតចង្រៃណាមួយ។

## តើខ្ញុំអាចបង្ការ ឬកម្ចាត់សត្វល្អិតចង្រៃបានដោយរបៀបណា?



អ្នកចាំបាច់ត្រូវធ្វើការពិនិត្យ ឬឱ្យអ្នកឯកទេសជំនាញមកពិនិត្យមើលសត្វល្អិតចង្រៃមុនពេលចូលមកស្នាក់នៅ។ អ្នកត្រូវតែរក្សាកំណត់ត្រាអំពីពេលវេលាដែលអ្នកបានត្រួតពិនិត្យ ការជួសជុលដែលអ្នកបានធ្វើ ផលិតផលដែលអ្នកបានប្រើ ទីកន្លែងដែលប្រើប្រាស់ផលិតផលនោះ និងកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញ។ ប្រសិនបើអ្នកទទួលបានការហៅទូរសព្ទពីអ្នកជួលផ្ទះពាក់ព័ន្ធនឹងសត្វល្អិតចង្រៃនៅក្នុងផ្ទះរបស់ពួកគេ អ្នកគួរតែត្រួតពិនិត្យទីតាំងអចលនទ្រព្យនោះ ឬឱ្យអ្នកឯកទេសជំនាញមកត្រួតពិនិត្យទីតាំងអចលនទ្រព្យឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។ បង្កើត និងអនុវត្តផែនការដាក់លាក់សម្រាប់ទីតាំងអចលនទ្រព្យ ដែលរួមបញ្ចូលទាំងវិធីបង្ការនិងកម្ចាត់សត្វល្អិតចង្រៃដោយប្រើ និងមិនប្រើសារធាតុគីមី។ ការបង្ការនិងកម្ចាត់ដោយមិនប្រើសារធាតុគីមីរួមមាន៖

**ឱ្យពួកវានៅក្រៅផ្ទះ៖**

- កាត់មែកឈើទាបៗ ឬទោរមក ដែលស្ថិតនៅជិតផ្ទះនោះ។
- បិទភ្ជិតស្នាមប្រេះ រន្ធ ឬច្រកចូលផ្សេងទៀតនៅជុំវិញខាងក្រៅផ្ទះនោះ។
- បិទចន្លោះនៅក្រោមទ្វារដោយដំឡើងបន្ទះបិទជើងទ្វារ។
- ជួសជុលអេក្រង់កញ្ចក់ដែលខូចនៅលើបង្អួចនិងទ្វារ។
- បិទចន្លោះជុំវិញបំពង់ទឹក បំពង់អគ្គិសនី បំពង់ប្រេង និងបំពង់ឧស្ម័នដែលអាចចូលមកក្នុងលំនៅឋានតាមជញ្ជាំង កម្រាលឥដ្ឋ និងពិដាន។

**ឱ្យពួកវាចេញផុតពីទីធ្លា៖**

- កាត់ស្មៅឱ្យខ្លី ព្រោះពពួកសត្វកកេរចូលចិត្តស្មៅខ្ពស់ៗ។
- ផ្តល់ឱ្យអ្នកជួលផ្ទះនូវធុងសំរាមការពារសត្វកកេរ ដោយមានគម្របគ្របដើម្បីជួយបំបាត់ប្រភពចំណីអាហារ។
- ប្រសិនបើមានធុងសំរាមធំក្រៅផ្ទះ ត្រូវប្រាកដថាពួកវាត្រូវបានបិទជិត និងគ្មានការធ្លុះធ្លាយ។ សូមប្រាកដថា ត្រូវដាក់សំរាមនៅខាងក្នុងធុងសំរាមក្រៅផ្ទះ – មិនត្រូវទុកនៅលើដីនៅជិតកន្លែងដែលសត្វល្អិតចង្រៃអាចចូលទៅក្នុងធុងបានដោយងាយឡើយ។
- ដាក់កំហិតអ្នកស្នាក់នៅកុំឱ្យប្រើឧបករណ៍ដាក់ចំណីបក្សីដែលនៅជិតផ្ទះ ដោយសារតែឧបករណ៍ទាំងនេះនឹងផ្តល់ចំណីដល់ពពួកសត្វកកេរ រួមជាមួយនឹងសត្វបក្សីផងដែរ។

**កុំផ្តល់ចំណី ឬទឹកឱ្យពួកវា៖**

- ជួសជុលជាបន្ទាន់នូវកន្លែងលេចធ្លាយទឹក។ លើកទឹកចិត្តអ្នកជួលផ្ទះឱ្យរាយការណ៍ពីការលេចធ្លាយ និងពន្យល់ពីមូលហេតុ។
- ជួសជុលទទឹក និងបំពង់បង្ហូរទឹក ដើម្បីឱ្យទឹកហូរចេញពីផ្ទះ។
- លើកទឹកចិត្តឱ្យអ្នកស្នាក់នៅរក្សាទុកអាហាររបស់ពួកគេនៅក្នុងធុងដែលគ្មានខ្យល់ចេញចូល សម្អាតកំទេចកំទីភ្លាមៗ និងគ្របសំរាមឱ្យជិត។

**ទីភ្នាក់ងារ EPA បាននិយាយថា វិធីល្អបំផុតក្នុងការកម្ចាត់សត្វល្អិតគឺ៖ បង្អត់ទឹកនិងចំណីពួកវា ហើយទុកពួកវាចោលខាងក្រៅ!**

## តើខ្ញុំអាចប្រើថ្នាំសម្លាប់សត្វល្អិតបានទេ?

ប្រសិនបើអ្នកមិនរស់នៅក្នុងទីតាំងអចលនទ្រព្យ ឬប្រសិនបើទីតាំងអចលនទ្រព្យមានបន្ទប់ចាប់ពី 4 ឡើងទៅ អ្នកត្រូវតែជួលអ្នកដាក់ថ្នាំសម្លាប់សត្វល្អិតដែលមានអាជ្ញាបណ្ណដើម្បីកម្ចាត់សត្វល្អិតចង្រៃទាំងនោះ។ ប្រសិនបើអ្នកជាម្ចាស់ទ្រព្យជួលដែលមាន 2 ឬ 3 បន្ទប់ ហើយអ្នករស់នៅក្នុងបន្ទប់ណាមួយ អ្នកអាចដាក់អង្គប់ នុយ និងដាក់ថ្នាំសម្លាប់សត្វល្អិតបាន។ ថ្នាំសម្លាត់សត្វល្អិតភាគច្រើនគឺជាថ្នាំពុល។ ប្រសិនបើគេមិនប្រើវាដោយប្រុងប្រយ័ត្នទេ វាអាចបង្កគ្រោះថ្នាក់ដល់អ្នក អ្នកជួលផ្ទះរបស់អ្នក និងសត្វចិញ្ចឹមផងដែរ។ នៅពេលប្រើថ្នាំសម្លាប់សត្វល្អិតណាមួយ៖

- សូមផ្តល់ការជូនដំណឹងដល់អ្នកស្នាក់នៅយ៉ាងហោចណាស់ 48 ម៉ោង និងរួមបញ្ចូលការត្រៀមលក្ខណ:សុវត្ថិភាពដែលពួកគេចាំបាច់ត្រូវធ្វើ។
- អានស្លាកសញ្ញា ហើយធ្វើតាមការណែនាំរបស់ក្រុមហ៊ុនផលិត។ កុំប្រើលើសពីការណែនាំ។
- ការពារខ្លួនអ្នក។ ស្លៀកសម្លៀកបំពាក់ដែលការពារស្បែករបស់អ្នក (អាវដៃវែង និងខោជើងវែង) និងឧបករណ៍ការពារខ្លួន (PPE) ដូចជាម៉ាស ឧបករណ៍ការពារភ្នែក និងស្រោមដៃសមរម្យ។
- ទុកថ្នាំគីមីសម្លាប់សត្វល្អិតក្នុងកន្លែងដែលមានសណ្តាប់ធ្នាប់ ស្ងួត និងមានសុវត្ថិភាព។
- ប្រាប់អ្នកស្នាក់នៅឱ្យបានជ្រាបថាតើអ្នកបានដាក់ថ្នាំសម្លាប់សត្វល្អិតនៅកន្លែងណា ហើយតើចាំបាច់ត្រូវមានបម្រុងប្រយ័ត្នផ្នែកសុវត្ថិភាពដែរឬទេ។
- កត់ត្រាអំពីពេលវេលាដែលអ្នកបានធ្វើការត្រួតពិនិត្យ ការជួសជុលដែលអ្នកបានធ្វើ ផលិតផលដែលអ្នកបានប្រើ ទីកន្លែងដែលបានប្រើប្រាស់ពួកវា និងកាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញ។
- ដាក់អង្គប់និងនុយនៅកន្លែងដែលកុមារ និងសត្វចិញ្ចឹមមិនអាចទៅដល់ពួកវា។
- ទប់ស្កាត់ការបំពុលសត្វព្រៃ និងសត្វចិញ្ចឹមដោយចៃដន្យ ដែលពួកវាអាចនឹងស៊ីសត្វងាប់ណាមួយ ហើយសូមសម្អាតនិងបោះចោលខ្មោចសត្វកកេរនោះជាបន្ទាន់។

## តើត្រូវជួលអ្នកឯកទេសជំនាញនៅពេលណា?

- ប្រសិនបើអ្នកបានព្យាយាម ហើយមិនអាចគ្រប់គ្រងការរាតត្បាតនោះបានទេ ឬប្រសិនបើបញ្ហាកើតឡើងម្តងទៀត អ្នកគួរតែពិចារណាជួលអ្នកជំនាញឯកទេស។
- ប្រសិនបើអ្នកមានជំងឺហឺត បញ្ហាផ្លូវដង្ហើម ឬប្រតិកម្មទៅនឹងសារធាតុគីមី អ្នកគួរតែជួលអ្នកជំនាញឯកទេសដើម្បីប្រើថ្នាំសម្លាប់សត្វល្អិត។
- អ្នកចាំបាច់ត្រូវជួលអ្នកជំនាញឯកទេស ប្រសិនបើអ្នកមិនរស់នៅក្នុងផ្ទះ ឬប្រសិនបើផ្ទះមានលើសពី 3 បន្ទប់។



### <u>តើអ្នកគួររំពឹងថានឹងទទួលបានអ្វីពីអ្នកកម្ចាត់សត្វល្អិតអាជីព?</u>

- ពួកគេត្រូវតែមានអាជ្ញាបណ្ណ និងស្គាល់ពីលិខិតបទដ្ឋានក្នុងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត។
- ពួកគេនឹងមកកាន់ទីតាំងអចលនទ្រព្យ ពិនិត្យមើលថាមានបញ្ហាអ្វីខ្លះ កំណត់លក្ខខណ្ឌដែលរួមចំណែកដល់ការរាតត្បាត និងកំណត់ថ្នាំសម្លាប់សត្វល្អិតឬអង្គប់ដែលល្អបំផុត ដើម្បីសម្លាប់សត្វល្អិតចង្រៃ។ ពួកគេនឹងផ្តល់ឱ្យអ្នកនូវកំណត់ត្រាអំពីការត្រួតពិនិត្យ ការប្រើថ្នាំ និងការត្រួតពិនិត្យឡើងវិញរបស់ពួកគេ។
- អាចនឹងត្រូវទៅជួបពិគ្រោះច្រើនដងដើម្បីដោះស្រាយបញ្ហានេះ។
- ពួកគេអាចនឹងត្រូវការចូលទៅកាន់ទាំងចំណែកទីតាំងរួម និងបន្ទប់ជាក់លាក់នានា។ អ្នកត្រូវតែផ្តល់ការជូនដំណឹងដល់អ្នកស្នាក់នៅក្នុងរយ:ពេល 48 ម៉ោងអំពីសកម្មភាពកម្ចាត់សត្វល្អិតនេះ។ សូមប្រាកដថាអ្នកស្នាក់នៅត្រៀមខ្លួនរួចរាល់ ហើយនឹងផ្តល់ការអនុញ្ញាតឱ្យចូលទៅកាន់ទីតាំងបន្ទប់ និងចំណែកទីតាំងជាក់លាក់ (ឧ. ទូខោអាវ)។

### <u>សុំពិនិត្យមើល៖</u>

- អាជ្ញាបណ្ណបច្ចុប្បន្នសម្រាប់អ្នកកម្ចាត់សត្វល្អិត។
- ស្លាកសញ្ញាសម្រាប់ផលិតផលដែលពួកគេនឹងប្រើប្រាស់។
    - ចូលទៅកាន់ http://npic.orst.edu/outreach/labelinfographic.jpg ដើម្បីស្វែងយល់អំពីស្លាកសញ្ញា។

### <u>អ្នកគួរតែដឹងអំពី៖</u>

- ទីកន្លែងដែលនឹងត្រូវប្រើថ្នាំសម្លាប់សត្វល្អិតនៅខាងក្នុង និងខាងក្រៅផ្ទះ។
- បុគ្គលដែលត្រូវហៅទូរសព្ទ ប្រសិនបើមានបញ្ហា (សូមមើលប្រអប់ពណ៌ខៀវនៅខាងស្តាំ)។


មានបញ្ហាមែនទេ? ទំនាក់ទំនង៖

ខ្សែទូរសព្ទសាកសួរព័ត៌មានអំពីថ្នាំសម្លាប់សត្វល្អិតទៅកាន់ទីភ្នាក់ងារ EPA៖
(800) 858-7378

មជ្ឈមណ្ឌលព័ត៌មានអំពីការបំពុលនៅរដ្ឋម៉ាសាឈូសិត៖ 1 (800) 222-1222

ប្រសិនបើប្រើប្រាស់អ្នកជំនាញឯកទេសប្រើថ្នាំសម្លាប់សត្វល្អិត សូមទាក់ទងទៅកាន់ផ្នែកអនុវត្តច្បាប់ថ្នាំសម្លាប់សត្វល្អិតនៅរដ្ឋម៉ាសាឈូសិតដើម្បីសួរនាំអំពីអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុននោះ៖
(617) 626-1781



**នាយកដ្ឋានសុខភាពសាធារណៈរដ្ឋម៉ាសាឈូសិត**
**ការិយាល័យសុខភាពអាកាសធាតុនិងបរិស្ថាន**

**កម្មវិធីអនាម័យសហគមន៍ (CSP)**
ទូរសព្ទ៖ 1-617-624-5757
TTY៖ 1-617-624-5286
អ៊ីមែល៖ communitysanitation@mass.gov
នៅលើគេហទំព័រ៖ www.mass.gov/community-sanitation